# ជួបជាមួយម្ចាស់អាជីវកម្មដែលទទួលបានកម្ចីមានការធានាពី CGCC

**“សហគ្រិនស្ត្រីនៅក្នុងវិស័យសំណង់-ការជម្នះផ្នត់គំនិតសង្គម ឆ្ពោះទៅការរីកចម្រើននៃអាជីវកម្ម ជាមួយនឹងកម្ចីដែលមានការធានា”**



លោកស្រី ដួង សុផាវី ម្ចាស់អាជីវកម្ម វីភី ផ្ទះចល័ត

“ការងារនេះមិនសាកសមនឹងស្ត្រីទេ។” នាងខ្ញុំតែងតែលឺមតិនេះ ពីមនុស្សជុំវិញខ្ញុំជាញឹកញយ ប៉ុន្តែនាងខ្ញុំមិនដែលរាថយនោះទេ។ ក្នុងឆ្នាំ២០១៨ នាងខ្ញុំបានចាប់ផ្តើមអាជីវកម្ម “វីភី ផ្ទះចល័ត” ដោយសាងសង់ផ្ទះ ការិយាល័យ ហាងកាហ្វេ និងសំណង់ផ្សេងៗទៀត ដែលអាចដឹកជញ្ជូនពីកន្លែងមួយទៅកន្លែងមួយទៀតបាន។ ក្នុងរយៈពេលមួយឆ្នាំដំបូង អាជីវកម្មរបស់ខ្ញុំនៅមិនមានទីផ្សារនោះទេ។ ដោយសារចិត្តស្រលាញ់ នាងខ្ញុំសុខចិត្តបោះបង់មុខរបរជាច្រើនមកចាប់យកអាជីវកម្មនេះ ហើយនៅតែប្រឹងប្រែងទាំងការធ្វើទីផ្សារបែបឌីជីថល ការប្រើប្រាស់ទុនដែលមានស្រាប់ផ្ទាល់ខ្លួនរបស់ខ្លួន និងការស្វែងរកទុនបន្ថែមពីគ្រឹះស្ថានហិរញ្ញវត្ថុ រហូតដល់អាជីវកម្មរបស់នាងខ្ញុំចាប់ផ្តើមមានការទទួលស្គាល់នៅដើមឆ្នាំ២០២០។



សព្វថ្ងៃនេះ ក្នុងមួយខែៗ ខ្ញុំទទួលបានការបញ្ជាទិញពីអតិថិជនប្រហែលពី ១០ ទៅ១៥ខ្នង ជាមធ្យម។ ស្របពេលជាមួយនឹងអាជីវកម្មរបស់ខ្ញុំមានការរីកចម្រើន ខ្ញុំពិតជាមានបញ្ហាស្ទះសាច់ប្រាក់ ដោយសារតែអតិថិជនបង់ប្រាក់កក់មកខ្ញុំត្រឹមតែ ៣០% នៃតម្លៃផ្ទះតែប៉ុណ្ណោះ ដូច្នេះខ្ញុំត្រូវការលុយបង្វិលឱ្យបានទាន់ពេលវេលា សម្រាប់បង្គ្រប់នូវថ្លៃចំណាយផ្នែកប្រតិបត្តិការនានា មុននឹងទទួលបានការទូទាត់ដែលនៅសេសសល់ពីអតិថិជន។ នាងខ្ញុំបានទៅរកធនាគារស្នើកម្ចីជាទុនបង្វិលសម្រាប់អាជីវកម្ម ប៉ុន្តែនាងខ្ញុំមិនមានទ្រព្យធានាដោយសាររាល់ទ្រព្យរបស់នាងខ្ញុំបានដាក់ធានាកម្ចីមុនៗអស់បាត់ទៅហើយ។ ពេលនោះ ខ្ញុំគិតថា បើគ្មានទ្រព្យបញ្ចាំទ្រព្យធានា ធនាគារនឹងមិនអាចផ្តល់កម្ចីមកឱ្យខ្ញុំបានទេ។ ប៉ុន្តែជាមួយការធានាឥណទានពី CGCC ខ្ញុំក៏បានទទួលកម្ចីអាជីវកម្មពីធនាគារស្ថាបនា ដោយមិនចាំបាច់ត្រូវការទ្រព្យធានា ។ បន្ទាប់ពីទទួលបានកម្ចីដែលមានការធានាពី CGCC ខ្ញុំបានយកវាទៅបន្ថែមជាទុនបង្វិល ដែលអាចឱ្យខ្ញុំអាចបន្តផ្តល់សេវាធ្វើផ្ទះចល័តជូនដល់អតិថិជនទាន់ពេលវេលា។



ការទទួលបានកម្ចីដែលមានការធានានេះ អាស្រ័យលើសក្តានុពលនៃអាជីវកម្មរបស់យើង ពោលគឺលទ្ធភាពនៃរីកចម្រើនទៅមុខ និងការកសាង និងថែទាំប្រវត្តិឥណទានឱ្យបានល្អ ក៏ដូចជាបំពេញគ្រប់នូវឯកសារតម្រូវ ដែលអាចបញ្ជាក់ពីភាពទុកចិត្ត និងការតាំងចិត្តរបស់ម្ចាស់អាជីវកម្មក្នុងការប្រើប្រាស់កម្ចីឱ្យចំគោលដៅ។ នាងខ្ញុំបានទទួលកម្ចីដោយជោគជ័យដើម្បីគាំទ្រដល់ការរីកចម្រើននៃអាជីវកម្មរបស់នាងខ្ញុំជាមួយការធានាឥណទានរបស់ CGCC ដោយដើរតួជាទ្រព្យធានាតាមរយៈគ្រឹះស្ថានធនាគារ/មីក្រូហិរញ្ញវត្ថុដៃគូរបស់ CGCC៕